**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# កោះស័ក្តិសិទ្ធ
# រយៈពេល ៣ ឆ្នាំ ( ២០១៨ - ២០២០ )

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | កោះស័ក្តិសិទ្ធ |
| ភូមិ | ៖ | កោះផ្ដៅ |
| ឃុំ | ៖ | កំពង់ចាម |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ កោះស័ក្តិសិទ្ធ

## រយៈពេល ៣ ឆ្នាំ ( ២០១៨ - ២០២០ )

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | កោះស័ក្តិសិទ្ធ |
| ភូមិ | ៖ | កោះផ្តៅ |
| ឃុំ | ៖ | កំពង់ចាម |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

# មាតិកា
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១-ស្ថានភាពទូទៅ**.......................................................................................................................៣

**២-អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម**.........................................................................................៤

ក- ប្រជាសាស្ត្រ.......................................................................................................................៤

ខ-មុខរបរ..............................................................................................................................៥

**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងសហគមន៍**.................................................៥

ក-ទីតាំង...............................................................................................................................៥

ខ-ដែននេសាទ.........................................................................................................................៥

គ-តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស..............................................................................៥

ឃ-ធនធានជលផល...................................................................................................................៦

**៤-ការធ្វើនេសាទ**.......................................................................................................................៦

ក-អ្នកនេសាទ..........................................................................................................................៦

ខ-ឧបករណ៍នេសាទ...................................................................................................................៦

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ......................................................................................៧

**៥-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**.................................................................................៨

ក-ទស្សនៈវិស័យ.......................................................................................................................៨

ខ-គោលបំណង.........................................................................................................................៨

គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍...................................................................................៩

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ.........................................................................................៩

គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍...............................................................................១០

គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ.........................................................................១១

គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត...............................................................................១២

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ...........................................................................១៣

គ៦-ផែនការផ្សព្វផ្សាយ..........................................................................................................១៤

គ៧-ផែនការបណ្តុះបណ្តាល......................................................................................................១៥

គ៨-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ...........................................................១៦

គ៩-ផែនការកែលម្អដែននេសាទ................................................................................................១៦

គ១០-ផែនការអភិវឌ្ឍវារីវប្បកម្ម.................................................................................................១៧

គ១១-ផែនការមុខរបរចិញ្ចឹមជីវិត................................................................................................១៧

ឃ.ផែនការយុទ្ធសាស្ត្រ...............................................................................................................១៨

-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ..............................................១៩

-តារាងកម្មវិធីការងារ.....................................................................................................................

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១-ស្ថានភាពទូទៅ

សហគមន៍នេសាទកោះស័ក្តសិទ្ធ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៨ ដោយខណ្ឌរដ្ឋបាលជលផលក្រចេះនិងគាំទ្រដោយអង្គការ CAA/Oxfam Australia បន្ទាប់មកបានបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញនៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១១ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រវាងខណ្ឌរដ្ឋបាលជលផលក្រចេះ និងគណៈកម្មការសហគមន៍នេសាទចំនួន២ អាណត្តិ លើទី១នៅថ្ងៃទី៣១ ខែកក្កដាឆ្នាំ២០១២និងបន្តអាណត្តិទី២ នៅថ្ងៃទី២៧កញ្ញា ឆ្នាំ២០១៦ ដែលរៀបចំឡើងដោយខណ្ឌរដ្ឋបាលជលផលក្រចេះនិងគាំទ្រថវិកាដោយអង្គការ WWF ។

សហគមន៍នេសាទកោះស័ក្តសិទ្ធ មានទីតាំងស្ថិតនៅក្នុងភូមិកោះផ្តៅ ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ ដែលមានសមាជិកសរុបចំនួន១១៤ នាក់ ស្រីចំនួន២៣ នាក់និងមានគណៈកម្មការចំនួន០៩ នាក់ ស្រីចំនួន០១ នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន ១៦៨ គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន៖

- បានបង្កើតកន្លែងអភិរក្សត្រីមេពូជ និងសត្វផ្សោត និងដាក់ស្លាកសញ្ញាចំនួន ០៥ ស្លាក
- បានបង្កើតក្រុមល្បាតសហគមន៍នេសាទ
- ធនាគារស្រូវ ធនាគារក្របី ក្រុមសន្សំប្រាក់

គាំទ្រដោយអង្គការ CAA/Oxfam Australia ។

បន្ទាប់មកទៀតសហគមន៍បានបង្កើតឱ្យមាន៖

- ក្រុមសន្សំប្រាក់
- ផ្ទះស្នាក់និងអេកូទេសចរណ៍សម្រាប់ទស្សនាសត្វផ្សោត
- បណ្តុះបណ្តាលការដាំដំណាំ សិប្បកម្មម្ហូប
- គណៈកម្មការទេសចរណ៍ធម្មជាតិ
- ស្រះចិញ្ចឹមត្រី ចិញ្ចឹមសត្វមាន់ ទា ជ្រូក
- ក្រុមសិល្បៈរបាំបូរាណ។ល។ដែលគាំទ្រដោយអង្គការ CRDT ។

ជាបន្តសហគមន៍បានចូលរួមបង្កើតបណ្តាញសហគមន៍នេសាទដើម្បី៖

- គាំទ្រពង្រឹងបណ្តាញសហគមន៍នេសាទនិងដំណើរការសហគមន៍នេសាទ
- បានបង្កើតប្រអប់គណនេយ្យភាពតាមឃុំ ។ល។ ដែលគាំទ្រដោយអង្គការ NRD ។

ជាបន្ទាប់សហគមន៍នេសាទបាន៖

- ពង្រឹង និងកែលម្អសកម្មភាពសហគមន៍អេកូទេសចរណ៍បន្ថែម ដើម្បីរកប្រាក់ចំណូលក្នុងសហគមន៍
- ផលិតសម្ភារៈ និងរូបភាពអប់រំផ្សព្វផ្សាយសហគមន៍អេកូទេសចរណ៍

ទំនាក់ទំនងជាមួយដៃគូពីខាងក្រៅដើម្បីជួយសហគមន៍អេកូទេសចរណ៍ដែលគាំទ្រដោយអង្គការ NTFP-EP ។

ដោយផុតអាណត្តិសហគមន៍បានស្នើសុំខណ្ឌរដ្ឋបាលជលផលក្រចេះបន្តះ

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញ
- បានរៀបចំឯកសារដើម្បីចុះបញ្ជីសហគមន៍នេសាទជាផ្លូវការដូចជាៈ
- បានបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- បានពិនិត្យកែសម្រួលលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណៈកម្មការសហគមន៍នេសាទ
- បានធ្វើផែនទីសហគមន៍នេសាទដោយមាននិយាមការច្បាស់លាស់សម្រាប់ដែនសហគមន៍និងអន្លង់អភិរក្សត្រី
- បានរៀបចំឯកសារចុះកិច្ចព្រមព្រៀង ផែនការគ្រប់គ្រងសហគមន៍នេសាទដែលទទួលស្គាល់ដោយថ្នាក់ជាតិ
- បានរៀបចំក្រុមល្បាតមានទូកកាណូត មានអាវពោង មានអាវភ្លៀងនិងពិលបំភ្លឺពេលយប់
- បានរៀបចំក្រុមល្បាត និងផែនការចុះល្បាតប្រចាំខែ
- បានធ្វើបង្គោលព្រំប្រទល់កន្លែងនេសាទសហគមន៍ចំនួន ៤ កន្លែងដែលឧបត្ថមគាំទ្រដោយអង្គការ WWF ។

នៅមុនពេលបង្កើតសហគមន៍នេសាទតែងតែមានបទល្មើសនេសាទកើតមាននៅក្នុងភូមិ និងបណ្តាលឱ្យធនធានជលផលមានការថយចុះជាលំដាប់។ ប៉ុន្តែបន្ទាប់ពីបានបង្កើតសហគមន៍នេសាទមក គណៈកម្មការសហគមន៍បានសហការជាមួយរដ្ឋបាលជលផល ប៉ូលីសប៉ុស្តិ៍ អាជ្ញាធរភូមិ ឃុំ ស្រុក និងឆ្មាំទន្លេចុះល្បាត និងបង្ក្រាបបទល្មើស ធ្វើឱ្យបទល្មើសនេសាទមានការថយចុះ ។

ទន្ទឹមនឹងនេះ ក៏នៅមានបទល្មើសនេសាទពីអ្នកខាងក្រៅសហគមន៍នេសាទលួចធ្វើនេសាទនៅកន្លែងអភិរក្ស ជាពិសេសនៅពេលយប់។ ដោយសហគមន៍នេសាទមានការខ្វះខាតប្រេងសម្រាប់ចាក់កាណូតចុះយាមល្បាតឱ្យបានទៀងទាត់ខ្វះទីស្នាក់ការសម្រាប់បំពេញការងារ ខ្វះសម្ភារៈសម្រាប់ចុះល្បាត។ ម៉្យាងវិញទៀតគណៈកម្មការសហគមន៍នេសាទពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគមន៍នេសាទ ហើយសមាជិកសហគមន៍នេសាទក៏នៅពុំទាន់មានការយល់ដឹង និងចូលរួមការងារសហគមន៍ឱ្យបានសស្រាក់សស្រាំផងដែរ ។

## ២-អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាសាស្ត្រ

-ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន ៨២២ នាក់ ប្រុសចំនួន ៤០៦ នាក់ ស្រី ៤១៦ នាក់ ក្នុងនោះជនជាតិខ្មែរ១០០%

-ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ២៨ នាក់

-ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ១៥ នាក់ ស្រី ៧ នាក់

-ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១៩ នាក់ ស្រី ១២ នាក់

-ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ១៨ នាក់ ស្រី ២ នាក់

-ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ២២ នាក់ ស្រី ១៦ នាក់

- ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%

-ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ៩៣ នាក់ ស្រី ៦១ នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន ១៨៧ នាក់ ស្រី ៩៤ នាក់ មធ្យមសិក្សា ៤៩ នាក់ ស្រី ២៧ នាក់ និងកំរិតថ្នាក់ឧត្តមសិក្សា ៧ នាក់ ស្រី ១ នាក់ ។

ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

-ធ្វើស្រែវស្សាចំនួន ១៦៣ គ្រួសារ  ទំហំ ១១៤,១០ ហិកតា (៧០%)

-ធ្វើនេសាទជាលក្ខណៈគ្រួសារ ចំនួន ១៤០ គ្រួសារ (៣០%)

-ដាំបន្លែចំនួន១៥ គ្រួសារ

-ធ្វើចំការចំនួន១៥ គ្រួសារ

-ធ្វើជាងផ្ទះចំនួន០៣ គ្រួសារ

-សិប្បកម្មម្ជូក កញ្ជើ កញ្ច្រែង ល្អីចំនួន០៣ គ្រួសារ

-លក់ដូរចាប់ហួយចំនួន១១ គ្រួសារ។

## ៣-កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

ក-ទីតាំង

កន្លែងនេសាទសហគមន៍ កោះស័ក្តសិទ្ធ ស្ថិតនៅតាមដងទន្លេមេគង្គលើ នៅក្នុងតំបន់ស្នូលទី៣ ក្នុងឃុំកំពង់ចាម ដែលកំណត់ដោយអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីការបង្កើតតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ ។

កន្លែងនេសាទសហគមន៍កោះស័ក្តសិទ្ធ មានទំហំ ៣២៩,១៥ ហិកតា និងមាននិយាមការដូច មានចែងនៅក្នុង កិច្ចព្រមព្រៀង។

មានព្រំប្រទល់៖

-ខាងជើងទល់នឹងភូមិកំពង់ក្របី

-ខាងត្បូងទល់នឹងភូមិសំភិន

-ខាងកើតទល់នឹងភូមិកោះផ្តៅ

-ខាងលិចទល់នឹងភូមិទន្សោងធ្លាក់ ។

ខ-ដែននេសាទ

កន្លែងនេសាទសហគមន៍ កោះស័ក្តសិទ្ធ ស្ថិតនៅតាមដងទន្លេមេគង្គ ដែលមានអន្លង់ កោះ និងព្រៃលិចទឹកដុះរាយនៅតាមមាត់ច្រាំងទន្លេ និងនៅតាមកោះ ។

គ-តំបន់ដែលបានបង្កើតកន្លែងអភិរក្ស

-អន្លង់អភិរក្សកោះផ្តៅតូច ទំហំ ១៧ ហិកតា

-អន្លង់អភិរក្សកោះផ្តៅធំ  ទំហំ ២៥ ហិកតា ។

ឃ-ធនធានជលផល

-ប្រភេទត្រី ៖

ត្រីខ្យា ត្រីឆ្លាំង ត្រីទ្រនេល ត្រីឆ្តោក ត្រីត្រសក់ ត្រីក្អែក ត្រីក្តី ត្រីក្រាយ ត្រីឆ្តោរ ត្រីរ៉ស់ ត្រីអំបូង ត្រីសណ្តាយ ត្រីក្លាំងហាយ ត្រីប្រា ត្រីកែស ត្រីប្រាកណ្តុរ ត្រីពោធិ៍ ត្រីព្រលូង ត្រីប៉ាវ៉ា ត្រីដំរី ត្រីប៉ាសុីអី ត្រីផ្ទក់ ត្រីឆ្លូញ ត្រីខ្ទឹង ត្រីរៀល ត្រីក្រទ្បង់ ត្រីកញ្ចុះ ត្រីគ្រំ ត្រីក្រាញ់ ត្រីកន្ទ្រប់ ត្រីឫសចេក ត្រីសារិកាកែវ ត្រីឆ្ពិន ត្រីកាហែ ត្រីច្រកែង ត្រីចង្វារ ត្រីអណ្តែង ត្រីស្លឹកឫស្សី ត្រីកំភ្លាវ ត្រីតាអោន ត្រីគល់រាំង ត្រីបបែល ត្រីលលកស ត្រីស្ទក់ ត្រីខ្មាន់ ត្រីកាទឹម ត្រីក្រុស ត្រីកញ្ជ្រូក ត្រីអាចម៍កុក ត្រីកំបុតច្រមុះ ត្រីកញ្ជូនជ័យ ត្រីក្របី ត្រីកែ ត្រីឈ្វាត ត្រកំពត ត្រីផ្តោង ត្រីអន្ទង់ ត្រីខ្លា ត្រីប្រម៉ា ត្រីរាហ៊ូ ត្រីអណ្តាតឆ្កែ ត្រីស្លាត ត្រីនាងល្វីង ត្រីកន្ត្រង់ប្រេង ត្រីរមាស ត្រីកំភ្លាញ ត្រីតាយ៉ូ។

-ប្រភេទវារីសត្វ ៖

កន្ធាយ អណ្តើក ល្មិច សត្វផ្សោត។

-ប្រភេទព្រៃលិចទឹក ៖

ដើមរៃ ដើមអណ្តែង ដើមអញ្ចាង ដើមអញ្ចេ ដើមទន្លា ដើមត្រស់ ដើមរាំង ដើមក្តុល ដើមផ្តៅ ដើមត្រែង ដើមស្លួត ដើមបបុស។

## ៤-ការធ្វើនេសាទ

**ក-អ្នកនេសាទ**

-អ្នកនេសាទជាសមាជិកសហគមន៍ ចំនួន ១១៤ នាក់ ស្រី ២៣ នាក់

-អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៤២០ នាក់

-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍មានចំនួន ៣០ នាក់ ស្រី ១០ នាក់។

ខ.ឧបករណ៍នេសាទ

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| សំណាញ់ | វង់ | ៨០ | ប្រវែង ៦ ម ក្រឡា ០,០១៦ ម | មករា ដល់ ធ្នូ |
| បង្កៃ | ផ្លែ | ១.០០០ | ផ្លែលេខ ៥-៦ | មិថុនា ដល់ ធ្នូ |
| សន្ទូចរនង | សាង(១០០ផ្លែ) | ១០០ | ផ្លែលេខ ៩-១២ | មករា ដល់ ធ្នូ |
| លប | លប | ៥០ | មុខ ១ ម បណ្តោយ ២ ម | មិថុនា ដល់ ធ្នូ |
| ចាន់ | ចាន់ | ៣០ | មុខ ០,៥ ម កម្ពស់ ១,៣ ម | មិថុនា ដល់ ធ្នូ |
| សន្ទូចបបក់ | ដង | ១០ | ផ្លែលេខ ៩-១២ | មិថុនា ដល់ ធ្នូ |
| ស្ទូរ | ដង | ៥ | ប្រវែង ២ ម | មិថុនា ដល់ ធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ៨ ទូក | ១០០-១៥០ គីឡូក្រាម | |
| ទូកមានម៉ាស៊ីន | ៥១ គ្រឿង | ២០០-៥០០ គីឡូក្រាម | ៥ សេះ - ១៨ សេះ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| សំណាញ់ | វង់ | ៣០ | ប្រវែង ៦ ម ក្រឡា ០,០១៦ ម | មករា ដល់ ធ្នូ |
| បង្កៃ | ផ្លែ | ២០០ | ផ្លែលេខ ៥-៦ | មិថុនា ដល់ ធ្នូ |
| សន្ទូចរនង | សាង(១០០ផ្លែ) | ២០ | ផ្លែលេខ ៩-១២ | មករា ដល់ ធ្នូ |
| លប | លប | ២០ | មុខ ១ ម បណ្តោយ ២ ម | មិថុនា ដល់ ធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ២០ គ្រឿង | ២០០-៥០០ គីឡូក្រាម | ៣,៥ សេះ - ៧,៥ សេះ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នក មិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| សំណាញ់ | វង់ | ១៥ | ប្រវែង ៦ ម ក្រឡា ០,០១៦ ម | មករា ដល់ មិថុនា |
| សន្ទូចរនង | សាង(១០០ផ្លែ) | ១០០ | ផ្លែលេខ ៩-១២ | មករា ដល់ មិថុនា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១៥ គ្រឿង | ៥០០ គីឡូក្រាម | ៧,៥ សេះ- ១៨ សេះ |

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៥៥ គីឡូក្រាម | ៧០គីឡូក្រាម | ១០៥គីឡូក្រាម |

**៥-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

ក-ទស្សនៈវិស័យ

សហគមន៍នេសាទ កោះស័ក្ខសិទ្ធ មានទស្សនវិស័យរួមចំណែកគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ-គោលបំណង

-ចូលរួមគ្រប់គ្រងកន្លែងនេសាទសហគមន៍កោះស័ក្ខសិទ្ធ

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍចំរុះដោយមានការចូលរួម

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទ ដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

គោលបំណង ៖ - ដើម្បីកំណត់ចំនួនឧបករណ៍នេសាទក្នុងសហគមន៍ឱ្យបានសមស្រប ជៀសវាងការធ្វើនេសាទហួសកម្រិតផលស្តុក

- ដើម្បីឱ្យសមាជិកសហគមន៍នេសាទ និងអ្នកនេសាទមកពីក្រៅសហគមន៍ធ្វើនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ទីតាំង និងពេលវេលានេសាទ

ផលរំពឹងទុក ៖ - ត្រីមេពូជ និងសត្វផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍

- ការនេសាទនៅកន្លែងអភិរក្ស និងឧបករណ៍នេសាទខុសច្បាប់ត្រូវបានហាមឃាត់។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | សកម្មភាព | គម្រោងថវិកា (ដុល្លា) | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|---|---|
| | | | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| នៅតាមដងទន្លេមេគង្គនៅខាងក្រៅអន្លង់អភិរក្សសហគមន៍ | ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់<br>១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ<br>១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | ២០០/ឆ្នាំ | មករា ដល់ ធ្នូ | សំណាញ់ | ប្រវែង ៦ម ក្រឡា០,០១៦ ម | ៨០ វង់ | |
| | | | | សន្ទូចរនង | លេខ ៩-១២ | ១០០ សាង | ១សាង (១០០ផ្លែ) |
| | | | មិថុនា ដល់ ធ្នូ | បង្កៃ | ផ្លែលេខ ៥-៦ | ១០០០ ផ្លែ | |
| | | | | លប | មុខ ១ ម បណ្តោយ ២ ម | ៥០លប | |
| | | | | ចាន់ | មុខ ០,៥ ម កម្ពស់ ១,៣ ម | ៣០ ចាន់ | |
| | | | | សន្ទូចបបក់ | ផ្លែលេខ ៩-១២ | ១០ ដង | |
| | | | | ស្ទូរ | ប្រវែង ២ ម | ៥ ស្ទូរ | មិនរួមផ្សំផ្លែ |

គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍

គោលបំណង ៖ - ដើម្បីបង្ហាញអ្នកនេសាទក្នុងសហគមន៍ និងក្រៅសហគមន៍ឱ្យបានដឹងពីទីតាំងកន្លែងអភិរក្សត្រីមេពូជ និងអភិរក្សសត្វផ្សោត
- ដើម្បីការពារត្រីមេពូជ និងសត្វផ្សោតនៅក្នុងសហគមន៍។

ផលរំពឹងទុក ៖ - ត្រីមេពូជ និងសត្វផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍
- ការនេសាទនៅកន្លែងអភិរក្សត្រូវបានហាមឃាត់។

ផែនការការពារកន្លែងអភិរក្សសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | សកម្មភាព | គម្រោងថវិកា (ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| អន្លង់អភិរក្សកោះផ្តៅតូច | ១៧ | ២.១-ដាក់ក្បូនឫស្សីស្លាកសញ្ញាសំគាល់ កន្លែងអភិរក្សចំនួន ៥ ស្លាក | ១០០ | ០១.០១.២០១៨ | ៣០.០៦.២០១៨ | ក្បូនឫស្សីត្រូវដាក់រៀងរាល់ឆ្នាំ រយៈពេល ៣ ឆ្នាំ |
| អន្លង់អភិរក្សកោះផ្តៅធំ | ២៥ | ២.២- ធ្វើបង្គោលព្រំប្រទល់កន្លែងអភិរក្សចំនួន ៤ បង្គោលអំពីដែកមានស្លាកសម្គាល់និងទង់ជាតិ | ៤០០ | ០១.០២.២០១៨ | ៣០.០២.២០១៨ | បង្គោលដែកចាក់ស៊ីម៉ង់ត៍ធ្វើតែម្តង |

គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ

គោលបំណង ៖ - ដើម្បីឱ្យគណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទមានឧបករណ៍ សម្ភារៈគ្រប់គ្រាន់ក្នុងការចុះល្បាត និងទប់ស្កាត់បទល្មើសនេសាទគ្រប់ប្រភេទ

- ដើម្បីឱ្យសហគមន៍នេសាទមានទីស្នាក់ការធ្វើការងាររដ្ឋបាល ប្រជុំការងារ ការទំនាក់ទំនង និងរក្សាទុកសម្ភារៈ និងឯកសារផ្សេងៗ ។

ផលរំពឹងទុក ៖ - គណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទអាចអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់

- សហគមន៍នេសាទមានទីស្នាក់ការសម្រាប់ទំនាក់ទំនងការងារ និងប្រចាំការ។

ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការសំភារៈ | ចំនួន | គម្រោងថវិកា(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | អាវពោង | ៥ អាវ | ១.៥០០ | ០១.០១.២០១៨ | ៣០.០១.២០១៨ | |
| | អាវភ្លៀង | ១៩ អាវ | | | | |
| | ភ្លើងហ្វាដាក់តាមកាណូត | ២ | | | | |
| | វិទ្យុទាក់ទង | ៣ | | | | |
| | អាគុយ | ១ | | | | |
| | ឯកសណ្ឋានអាវ និងមួកសម្រាប់ល្បាត | ១៩ | | | | |
| | ម៉ាស៊ីនថត | ១ | | | | |
| | ហិបសហគមន៍ | ១ | | | | |
| ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | ទីស្នាក់ការទំហំ ៦មX៤ម | ១ | ២.០០០ | ០១.១២.២០១៨ | ៣០.១២.២០១៨ | |

គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត

គោលបំណង ៖- ដើម្បីឱ្យគណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទ ប្រជុំបូកសរុបលទ្ធផលដែលបានអនុវត្ត លើកបញ្ហាផ្សេងដែលបានជួបប្រទះ លើកផែនការអនុវត្តន៍បន្ត

- ធ្វើរបាយការណ៍ពីលទ្ធផលការងារ ការលំបាក ការងាយស្រួល ទៅអាជ្ញាធរឃុំ ស្រុក ខណ្ឌរដ្ឋបាលជលផលដើម្បីជួយដោះស្រាយ ។

ផលរំពឹងទុក ៖- សហគមន៍នេសាទអាចដំណើរការគ្រប់គ្រងមានប្រសិទ្ធភាព

- បញ្ហាលំបាកផ្សេងដែលកើតមាននៅក្នុងសហគមន៍នេសាទត្រូវបានដោះស្រាយ និងលើកទិសដៅអនុវត្តបន្ត។

ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | អ្នកចូលរួម | គម្រោងថវិកា(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | - គណៈកម្មការសហគមន៍នេសាទ<br>- ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍<br>- ឆ្នាំទន្លេ<br>- រដ្ឋបាលជលផល | ៣៥/ខែ<br>១ឆ្នាំ=៣៥X១២=៤២០ | ២៤.០១.២០១៨ | ២៤.១២.២០២០ | ប្រជុំរៀងរាល់ខែរយៈពេល ៣ ឆ្នាំ |
| ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | - គណៈកម្មការសហគមន៍នេសាទ<br>- ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍<br>- ឆ្នាំទន្លេ<br>- សមាជិកសហគមន៍<br>- អាជ្ញាធរមូលដ្ឋាន<br>- រដ្ឋបាលជលផល | ៦០០ | ១២.១២.២០១៨ | ១២.១២.២០២០ | មួយឆ្នាំម្តង |
| ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | - គណៈកម្មការសហគមន៍នេសាទ | ៥០០ | ០១.១១.២០២០ | ៣០.១២.២០២០ | [illegible] |

| | | | | | |
|---|---|---|---|---|---|
| | - ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍<br>- ឆ្មាំទន្លេ<br>- រដ្ឋបាលផលផល<br>- អាជ្ញាធរមូលដ្ឋាន | | | | |

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ

គោលបំណង ៖ - ដើម្បីឱ្យសហគមន៍នេសាទទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទក្នុងសហគមន៍ឱ្យមានប្រសិទ្ធភាព

- សហគមន៍នេសាទមានមធ្យោបាយគ្រប់គ្រាន់សម្រាប់ទប់ស្កាត់បទល្មើសនេសាទ។

ផលរំពឹងទុក ៖ - សហគមន៍នេសាទមានការយាមល្បាតទៀងទាត់

- បទល្មើសនេសាទនៅក្នុងសហគមន៍ត្រូវបានកាត់បន្ថយឱ្យបទល្មើសនេសាទមានការថយចុះជាលំដាប់។

ផែនការចុះទប់ស្កាត់បទល្មើសនេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការសំភារៈ | គម្រោងថវិកា (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៥.១-ចុះល្បាតចំនួន ៦ ដង ក្នុង១ ខែនៅរដូវប្រាំង (៦ ដងx៦ ខែX៤ លីត្រ=១៤៤លីត្រ) | - ប្រេងសាំងចំនួន ១៤៤ លីត្រ<br>- ប្រេងម៉ាស៊ីន ចំនួន ៨ លីត្រ | ២២០ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍<br>- ឆ្មាំទន្លេ | ០១.០១.២០១៨ | ៣០.០៦.២០២០ | ល្បាតរៀងរាល់ឆ្នាំ រយៈពេល ៣ ឆ្នាំ |
| ៥.២-ចុះល្បាតចំនួន ៤ ដងក្នុង១ ខែ នៅរដូវវស្សា (៤ ដងx៦ ខែX៤ លីត្រ=៩៦ លីត្រ) | - ប្រេងសាំងចំនួន ៩៦ លីត្រ<br>- ប្រេងម៉ាស៊ីន ចំនួន ៤ លីត្រ | ១៤០ | | ០១.០៧.២០១៨ | ៣០.១២.២០២០ | ល្បាតរៀងរាល់ឆ្នាំ រយៈពេល ៣ ឆ្នាំ |

គ៦-ផែនការផ្សព្វផ្សាយ

គោលបំណង ៖ ដើម្បីឱ្យសមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងពីឯកសារផ្សេងៗ របស់សហគមន៍ និង ប្រកាស អនុក្រឹត្យ និងច្បាប់ផ្សេងដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

ផលរំពឹងទុក ៖ សមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងហើយចូលរួមគាំទ្រ និងអនុវត្តន៍ឱ្យមានប្រសិទ្ធភាព។

ផែនការផ្សព្វផ្សាយច្បាប់ជលផល ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ | គម្រោងថវិកា(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | -ឯកសារផ្សព្វផ្សាយ<br>-គ្រូបង្គោល | ៦០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល សមាជិកសហគមន៍នេសាទ | ០១.០១.២០១៨ | ០១.០២.២០២០ | សម្រាប់ ៣ឆ្នាំ |
| ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀង ប្រកាសស្តីពីការចុះបញ្ជីសហគមន៍នេសាទនិងផែនទីកន្លែងនេសាទសហគមន៍ | | ៦០០ | | ០១.០១.២០១៨ | ០១.០២.២០២០ | សម្រាប់ ៣ឆ្នាំ |
| ៦.៣-ផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | ៦០០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងប្រកាសពាក់ព័ន្ធផ្សេងៗ | | ៦០០ | | ០១.០៥.២០១៨ | ៣០.០៦.២០២០ | |
| ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់គ្រប់គ្រងនិងការពារសត្វផ្សោត និងបរិស្ថាន | | ៦០០ | | ០១.០៥.២០១៨ | ៣០.០៦.២០២០ | |
| ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍នេសាទ | | ៦០០ | | ០១.១២.២០១៨ | ៣០.១២.២០២០ | |

គ៧-ផែនការបណ្តុះបណ្តាល

គោលបំណង ៖ ផ្តល់ចំណេះដឹងពីការងាររដ្ឋបាល ការងារធ្វើផែនការ ការងារដឹកនាំ និងនីតិវិធីកសាងឯកសារនានាដល់គណៈកម្មការសហគមន៍នេសាទ។

លទ្ធផលរំពឹងទុក៖ គណៈកម្មការសហគមន៍នេសាទមានសមត្ថភាពក្នុងការដឹកនាំ ការគ្រប់គ្រង និងការកសាងឯកសារសំណុំរឿងបទល្មើសជលផល។

ផែនការបណ្តុះបណ្តាល ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ | គម្រោងថវិកា(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុ និងរបាយការណ៍ | -ឯកសារបណ្តុះបណ្តាល<br>-គ្រូបណ្តុះបណ្តាល | ៣៥០ | គណៈកម្មការអាជ្ញាធរមូលដ្ឋានក្រុមល្បាត | ០១.០១.២០១៨ | ០១.០២.២០១៨ | |
| ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០១៨ | |
| ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |
| ៧.៤-បណ្តុះបណ្តាលអំពីការតាមដាន និងវិភាគគុណភាពទឹក | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |
| ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធីនិងការកសាងសំណុំរឿងបទល្មើសនេសាទបឋម | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |

គ៨-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

គោលបំណង ៖ ដើម្បីប្រមូលថវិកាពីសមាជិកមកប្រើប្រាស់សម្រាប់ការងារគ្រប់គ្រងសហគមន៍។

លទ្ធផលរំពឹងទុក ៖ សហគមន៍នេសាទនឹងមានថវិកាមកទ្រទ្រង់ការងារគ្រប់គ្រងសហគមន៍នេសាទ។

ផែនការចំណូលថវិកាទ្រទ្រង់សហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលសរុប (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|
| ៨.១-ភាគទានពីសមាជិកសហគមន៍នេសាទដែលទើបនឹងចូលថ្មី | ប្រមូលភាគទានពីសមាជិកដែលចូលថ្មី | ០១.០១.២០១៨ | ០១.១២.២០២០ | ១០០.០០០ | ១.០០០ រៀល/នាក់ |
| ៨.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | ប្រមូលភាគទានប្រចាំឆ្នាំពីសមាជិក | ០១.០១.២០១៨ | ០១.១២.២០២០ | ៣៨២.០០០ | ១.០០០ រៀល/នាក់ រយៈពេល៣ឆ្នាំ |
| ៨.៣- ធ្វើផែទេសចរណ៍កំសាន្តស្វែងរកចំណូលគាំទ្រសហគមន៍ | ប្រជុំនិងរៀបចំកន្លែងទេសចរណ៍កំសាន្តនិងស្វែងរកជំនួយ | ០១.០៣.២០១៨ | ០១.០៣.២០២០ | | កិច្ចសហការសមាជិកសហគមន៍នេសាទ |
| ៨.៤-ហិបរៃអង្គៀសថវិកា | ធ្វើហិបរៃអង្គៀសថវិការនិងដាក់តាមកន្លែងទេសចរណ៍, បុណ្យ, វត្ត ។ល។ | ០១.០៣.២០១៨ | ០១.០៣.២០២០ | | កិច្ចគាំទ្រពីស្ថាបន័ពាក់ពន័ និងមនុស្សសំខាន់ |

គ៩-ផែនការកែលំអរដែននេសាទ

សំគាល់ ៖ ដោយកន្លែងនេសាទសហគមន៍ស្ថិតនៅតាមដងទន្លេមេគង្គពុំមានផែនការត្រូវកែលម្អឡើយ ។

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |

គ១០-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

កំណត់សំគាល់ ៖ ទីតាំងសហគមន៍នេសាទស្ថិតនៅក្នុងតំបន់ស្នូលទី៣ ក្នុងឃុំកំពង់ចាម ដែលកំណត់ដោយអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ ពុំអនុញ្ញាតឱ្យធ្វើ វារីវប្បកម្មបែ ឬសិងក្នុងតំបន់ស្នូលនៅរដូវប្រាំង ម្យ៉ាងវិញទៀតនៅតំបន់នេះ ជាប្រភេទដីមិនគត់ទឹកនៅរដូវប្រាំង ។

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រី | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| | | | | | |

គ១១-ផែនការមុខរបរចិញ្ចឹមជីវិត

គោលបំណង ៖ -ដើម្បីធ្វើឱ្យគណៈកម្មការនិងសមាជិកសហគមន៍នេសាទ ទទួលបានប្រាក់ចំណូល និងជីវភាពបានប្រសើរឡើងតាមរយៈការអភិវឌ្ឍចម្រុះដោយមានការចូលរួម ដើម្បីឈានដល់ការកាត់បន្ថយភាពក្រីក្រ និងការនេសាទក្នុងតំបន់អភិរក្សសត្វផ្សោត។

លទ្ធផលរំពឹងទុក ៖ គណៈកម្មការសហគមន៍នេសាទ និងសមាជិកមានមុខរបរ ទទួលបានប្រាក់ចំណូល ជីវភាពត្រូវបានប្រសើរឡើង និងការធ្វើនេសាទនៅក្នុងតំបន់ស្នូលជាតំបន់អភិរក្សសត្វផ្សោត ត្រូវបានកាត់បន្ថយ ។

ផែនការបង្កើតមុខរបរចម្រុះ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ | គម្រោងថវិកា(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១១.១-បណ្តុះបណ្តាលវគ្គចិញ្ចឹមជ្រូក មាន់ ទា | -គ្រូបណ្តុះបណ្តាល<br>- ឯកសារបណ្តុះបណ្តាល<br>- ថវិកាទុន | ៤០០០ | គ្រូបណ្តុះបណ្តាល គណៈកម្មការ និងសមាជិសហគមន៍ដែលជាក្រុមគោដៅពី១៥ទៅ២០នាក់ | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ១១.២-បណ្តុះបណ្តាលក្រុមបណ្តុះផ្សិតចំបើង | | ១៥០០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ១១.៣-បណ្តុះបណ្តាលក្រុមសន្សំប្រាក់ ឬក្រុមជួយខ្លួនឯង | | ២០០០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |

### ឃ.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម :

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណា ដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំផែនការអនុវត្តតាមដំណាក់កាលនីមួយៗដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការណ៍ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែការអភិវឌ្ឍឃុំ សង្កាត់។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កោះស័ក្តិសិទ្ធ រយៈពេល៣ឆ្នាំ (២០១៨ ដល់ ២០២០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លា) | ប្រភពជំនួយ | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | - ត្រីមេពូជ និងផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍។<br>- ការនេសាទនៅកន្លែងអភិរក្ស និងឧបករណ៍នេសាទខុសច្បាប់ត្រូវបានហាមឃាត់។ | ២០០/ឆ្នាំ | អង្គការដៃគូ<br>រដ្ឋបាលជលផល<br>ថវិកាសហគមន៍ | ០១.០១.២០១៨ | ៣០.០១.២០២០ | |
| | ១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ | | | | ០១.០១.២០១៨ | ៣០.០១.២០២០ | |
| | ១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | | | | ០១.០១.២០១៨ | ៣០.១២.២០២០ | |
| គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍ | ២.១-ដាក់ក្បូនឫស្សីស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៥ ស្លាក | - ត្រីមេពូជ និងផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍។<br>- ការនេសាទនៅកន្លែងអភិរក្សត្រូវបានហាមឃាត់។ | ១០០/ឆ្នាំ | អង្គការដៃគូ<br>រដ្ឋបាលជលផល | ០១.០១.២០១៨ | ៣០.០៦.២០១៨ | រៀងរាល់ឆ្នាំ |
| | ២.២-ធ្វើបង្គោលព្រំប្រទល់កន្លែងអភិរក្សចំនួន ៤ បង្គោលអំពីដែកមានស្លាកសម្គាល់និងទង់ជាតិ | | ៤០០/ឆ្នាំ | | ០១.០២.២០១៨ | ៣០.០២.២០១៨ | |
| គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ | ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | - គណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទអាចអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់។<br>- សហគមន៍នេសាទមានស្នាក់ការសម្រាប់ទំនាក់ទំនងការងារនិងប្រចាំការ។ | ១.៥០០ | អង្គការដៃគូ<br>រដ្ឋបាលជលផល | ០១.០២.២០១៨ | ៣០.០២.២០២០ | |
| | ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | | ២.០០០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត | ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | -សហគមន៍នេសាទអាចដំណើរការគ្រប់គ្រងមានប្រសិទ្ធភាព។ -បញ្ហាលំបាកផ្សេងដែលកើតមាននៅក្នុងសហគមន៍នេសាទត្រូវបានដោះស្រាយ និងលើកទិសដៅអនុវត្ត ។ | ៤២០/ឆ្នាំ | អង្គការដៃគូ រដ្ឋបាលជលផល ថវិកាសហគមន៍ | ២៤.០១.២០១៨ | ២៤.១២.២០២០ | ប្រជុំរៀងរាល់ខែ |
| | ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | | ៦០០/ឆ្នាំ | | ១២.១២.២០១៨ | ១២.១២.២០២០ | មួយឆ្នាំម្តង |
| | ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | | ៥០០ | | ០១.១១.២០២០ | ៣០.១២.២០២០ | បីឆ្នាំម្តង |
| គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ | ៥.១-ចុះល្បាតចំនួន ៦ ដង ក្នុង១ខែនៅរដូវប្រាំង | -សហគមន៍នេសាទមានការយាមល្បាតទៀងទាត់។ -បទល្មើសនេសាទនៅក្នុងសហគមន៍ត្រូវបានថយចុះ ។ | ៤២០ ក្នុងរដូវប្រាំង ក្នុង១ឆ្នាំ | អង្គការដៃគូ រដ្ឋបាលជលផល | ០១.០១.២០១៨ | ៣០.០៦.២០២០ | |
| | ៥.២-ចុះល្បាតចំនួន ៤ ដងក្នុង១ ខែនៅរដូវវស្សា | | ១១០ ក្នុងរដូវវស្សា ក្នុង១ឆ្នាំ | | ០១.០៧.២០១៨ | ៣០.១២.២០២០ | |
| គ៦-ផែនការផ្សព្វផ្សាយ | ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | សមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងហើយចូលរួមគាំទ្រ និងអនុវត្តឱ្យមានប្រសិទ្ធភាព។ | ៣៥០ | អង្គការដៃគូ រដ្ឋបាលជលផល | ០១.០១.២០១៨ | ០១.០២.២០២០ | ១ឆ្នាំម្តង |
| | ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀងប្រកាសស្តីពីការចុះបញ្ជីសហគមន៍ និងផែនទីកន្លែងនេសាទសហគមន៍ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| | ៦.៣-ផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| | ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងប្រកាសពាក់ព័ន្ធផ្សេងៗ | | ៣៥០ | | ០១.០៥.២០១៨ | ៣០.០៦.២០២០ | |
| | ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គនិង បរិស្ថាន | | ៣៥០ | | ០១.០៥.២០១៨ | ៣០.០៦.២០២០ | |
| | ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍នេសាទ | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៧-ផែនការបណ្តុះបណ្តាល | ៧.១-បណ្តុះបណ្តាលអំពីរបៀបសរសេរកំណត់ហេតុ និងរបាយការណ៍ | គណៈកម្មការសហគមន៍នេសាទមានសមត្ថភាពក្នុងការដឹកនាំការគ្រប់គ្រង និងការកសាងឯកសារសំណុំរឿងបទល្មើសជលផល។ | ៣៥០ | អង្គការដៃគូ រដ្ឋបាលជលផល | ០១.០១.២០១៨ | ០១.០២.២០១៨ | |
| | ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០១៨ | |
| | ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៣៥០ | | ០១.០១.២០១៨ | ៣០.០២.២០១៨ | |
| | ៧.៤-បណ្តុះបណ្តាលអំពីការតាមដាន និងវិភាគគុណភាពទឹក | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |
| | ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និងការកសាងសំណុំរឿងបទល្មើសជលផលបឋម | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |
| គ៨-ផែនការចំណូលថវិកា | ៨.១-ភាគទានពីសមាជិកសហគមន៍នេសាទដែលទើបនឹងចូលថ្មី | សហគមន៍នេសាទនឹងមានថវិកាមកទ្រទ្រង់ការងារគ្រប់គ្រងសហគមន៍នេសាទ។ | ២០ | ថវិកាសហគមន៍ | ០១.០១.២០១៨ | ០១.១២.២០២០ | |
| | ៨.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | | ៣០ | | ០១.០១.២០១៨ | ០១.១២.២០២០ | |
| | ៨.៣- ធ្វើផែនទេសចរណ៍កំសាន្តស្វែងរកចំណូលគាំទ្រសហគមន៍ | មានភ្ញៀវទេសចរណ៍មកកំសាន្តផែ សហគមន៍មានកំរៃ | | | ០១.០៣.២០១៨ | ០១.០៣.២០២០ | |
| | ៨.៤- ធ្វើហិបរៃអង្គៀសថវិកានិងដាក់តាមកន្លែងទេសចរណ៍, បុណ្យ, វត្ត ។ល។ | មានសប្បុរសជនវិភាគទានថវិកាសម្រាប់សហគមន៍ការពារអភិរក្សត្រីនិងសត្វផ្សេងៗ។ | | | ០១.០៣.២០១៨ | ០១.០៣.២០២០ | |
| គ១១-ផែនការមុខរបរចិញ្ចឹមជីវិត | ១១.១-បណ្តុះបណ្តាលវគ្គចិញ្ចឹម ជ្រូក មាន់ ទា ដាំបន្លែ | សមាជិកសហគមន៍មានជំនាញមានមុខរបរ និងអាចរកប្រាក់ | ៦០០ | អង្គការដៃគូ រដ្ឋបាលជលផល ថវិកាសហគមន៍ | ០១.០២.២០១៨ | ០១.០៣.២០២០ | |
| | ១១.២-បណ្តុះបណ្តាលក្រុមបណ្តុះផ្សិតចំបើង | | ៦០០ | | ០១.០២.២០១៨ | ០១.០៣.២០២០ | |
| | ១១.៣-បណ្តុះបណ្តាលក្រុមសន្សំប្រាក់ឬក្រុមជួយខ្លួនឯង | | ៦០០ | | ០១.០២.២០១៨ | ០១.០៣.២០២០ | |

# តារាងកម្មវិធីការងារ

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៨ | | | | | | | | | | | | ២០១៩ | | | | | | | | | | | | ២០២០ | | | | | | | | | | | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| **គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទ ឧបករណ៍នេសាទហាមឃាត់ | → | | | | | | | | | | | | → | | | | | | | | | | | | → | | | | | | | | | | | |
| ១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | → |
| **គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.១-ដាក់ក្បូនឬស្សីស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៦ ស្លាក | — | — | — | — | — | → | | | | | | — | — | — | — | — | — | → | | | | | | — | — | — | — | — | — | → | | | | | | → |
| ២.២-ធ្វើបង្គោលព្រំប្រទល់កន្លែងអភិរក្សចំនួន ៤ បង្គោល | | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | | → | | | | | | | | | | | | → | | | | | | | | | | | | → | | | | | | | | | | |

| | | | |
|---|---|---|---|
| ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | → | | |
| **គ៤-ផែនការប្រជុំគណៈ កម្មការ និងក្រុមល្បាត** | | | |
| ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | → | → | → |
| ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | → | → | → |
| ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | | | → |
| **គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ** | | | |
| ៥.១-ចុះល្បាតចំនួន ៦ ដង ក្នុង១ ខែនៅរដូវប្រាំង | → | → | → |
| ៥.២-ចុះល្បាតចំនួន ៤ ដង ក្នុង១ ខែ នៅរដូវវស្សា | → | → | → |
| **គ៦-ផែនការផ្សព្វផ្សាយ** | | | |
| ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងហគមន៍នេសាទ | → | → | → |
| ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀងប្រកាសស្តីពីការចុះបញ្ជីសហគមន៍និងផែនទីកន្លែងនេសាទសហគមន៍ | → | → | → |
| ៦.៣-ផ្សព្វផ្សាយផែនការគ្រប់ | → | → | → |

| គ្រងកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផលនិងប្រកាសពាក់ព័ន្ធ | | | | | → | | | | | | | | | | | | → | | | | | | | | | | | | → | | | | | | | |
| ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គនិង បរិស្ថាន | | | | | → | | | | | | | | | | | | → | | | | | | | | | | | | → | | | | | | | |
| ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍នេសាទ | | | | | | | | | | | | → | | | | | | | | | | | | → | | | | | | | | | | | | → |
| **គ៧-ផែនការបណ្តុះ បណ្តាល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.១-បណ្តុះបណ្តាលអំពីរបៀបសរសេរកំណត់ហេតុ និងរបាយការណ៍ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.៤-បណ្តុះបណ្តាលអំពីការតាមដាន វិភាគគុណភាពទឹក | | | | | | | | | | | | → | | | | | | | | | | | | | | | | | | | | | | | | |
| ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និងការកសាងសំណុំរឿងបទល្មើសជលផលបឋម | | | | | | | | | | | | → | | | | | | | | | | | | | | | | | | | | | | | | |
| **គ៨-ផែនការចំណូល ថវិកា** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.១-ភាគទានពីសមាជិកសហគមន៍ដែលទើបនឹងចូលថ្មី | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |

| | |
|---|---|
| ៨.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | |
| ៨.៣- ធ្វើផែនទេសចរណ៍កំសាន្តស្វែងរកចំណូលគាំទ្រស/គ | |
| ៨.៤- ធ្វើហិបរៃអង្កៀសថវិកានិងដាក់តាមកន្លែងទេសចរណ៍, បុណ្យ, វត្ត ។ល។ | |
| **គ១១-ផែនការមុខរបរចិញ្ចឹមជីវិត** | |
| ១១.១-បណ្តុះបណ្តាលវគ្គចិញ្ចឹមជ្រូក មាន់ ទា ដាំបន្លែ | |
| ១១.២-បណ្តុះបណ្តាលក្រុមបណ្តុះផ្សិតចំបើង | |
| ១១.៣-បណ្តុះបណ្តាលក្រុមសន្សំប្រាក់ ឬក្រុមជួយខ្លួនឯង | |

សូមគោរពជូនលោក
មេឃុំកំពង់ចាម
" ដើម្បីពិនិត្យ និងសម្រួល "
កោះផ្តៅ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១៧
**ប្រធានគណៈកម្មការសហគមន៍នេសាទ**
**កោះស័ក្តសិទ្ធ ភូមិកោះផ្តៅ**

ម៉ុំ. កុសល.

លេខ : 160/17 ឃកច.
បានឃើញ និងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលកាំពី
" ដើម្បីពិនិត្យ និងសម្រួល"
កំពង់ចាម ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៧
**មេឃុំកំពង់ចាម**

រឿត_ណាន

លេខ : ០១៥ ដជ.កចា
បានឃើញ និងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ
" ដើម្បីពិនិត្យ និងសម្រួល"
កាំពី ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០១៧
**នាយផ្នែករដ្ឋបាលជលផលកាំពី**

ញឹម កុល

លេខ :១៥០ រដ.ក្រច

បានឃើញ និងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

" ដើម្បីពិនិត្យ និងសម្រួល"

ក្រចេះ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧

**នាយខណ្ឌរដ្ឋបាលជលផលក្រចេះ**

**សៀន គិន**

លេខ :៤៥៦ កសរន-ក្រច

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ក្រចេះ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៧

**ប្រធាន**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ**

**គុយ_ហួត**

លេខ :១៣៤៥ ជផ

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ .ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១៧

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**